**មាតិកា មួយ**

**ជំពូក ពីរ**

**បទល្មើស ប្រឆាំងនឹង សាសនា របស់រដ្ឋ**

**មាត្រា ២០៩** - ការព្យាបាទ ដល់ជីវិត របស់បុព្វជិត ក្នុងសាសនា របស់រដ្ឋ នៅវេលាដែលលោកកំពុងធ្វើវត្តប្រតិបត្តិ ឬ នៅឱកាសដែលលោក ធ្វើវត្តប្រតិបត្តិតាមច្បាប់ សាសនាត្រូវមានទោសឧក្រិដ្ឋថ្នាក់ទី បី។

**មាត្រា ២១០** - ការព្យាបាទ ដល់រូបកាយ របស់បុព្វជិត ក្នុងសាសនា របស់រដ្ឋ នៅវេលាដែលលោក កំពុងធ្វើវត្តប្រតិបត្តិ ឬ នៅឱកាស ដែលលោក ធ្វើវត្តប្រតិបត្តិ តាមច្បាប់សាសនាត្រូវមានទោសឧក្រិដ្ឋ ថ្នាក់ទីពីរ។

**មាតិកា ពីរ**

**អំពី បទល្មើស ប្រព្រឹត្ត លើជនសាមញ្ញ**

**ជំពូក មួយ**

**អំពី បទល្មើស ប្រព្រឹត្ត លើរូបកាយ ជនសាមញ្ញ**

**មាត្រា ៥០០** - ជនណា ធ្វើទារុណកម្ម អ្នកដទៃ ដើម្បីអោយអ្នកនោះ ឈឺជាខ្លាំង ហើយធ្លាយប្រាប់ ពត៌មានផ្សេងៗ ដែលមានប្រយោជន៍ ដល់ការប្រព្រឹត្ត ឧក្រិដ្ឋកម្ម មជ្ឈឹមកម្ម ណាមួយក្តីដើម្បីសងសឹក ឬ ដោយអំពើចិត្តព្រៃ របស់ខ្លួនក្តី ជននោះត្រូវមានទោស ឧក្រិដ្ឋថ្នាក់ទីបី។

**មាត្រា ៥០១** - ជនណា ធ្វើអោយគេស្លាប់ ជននោះមានពិរុទ្ធ ក្នុងបទ មុនស្សឃាត ។ បើស្លាប់នោះ បណ្តាលមកពី អំពើឥតចេតនាទេ អំពើនោះឈ្មោះថា មនុស្សឃាតដោយអចេតនា។

បើស្លាប់ បណ្តាលមកពី អំពើប្រកបដោយចេតនា ចង់សំលាប់គេ អំពើនោះ ឈ្មោះថាមនុស្សឃាតចេតនា។

**មាត្រា ៥០២** - មនុស្សឃាត ដោយអចេតនាណា បណ្តាលមកពី កំហុសទាំងឡាយ គឺមិនប្រយ័ត្ន មិនប្រសប់ ធ្វេសប្រហែស ឬ មិនគោរពតាមបទបញ្ជាមនុស្សឃាត ដោយអចេតនានោះត្រូវមានទោស ទៅតាមប្រភេទ នៃកំហុសរបស់វាផ្សេងៗគ្នា យ៉ាងនេះ៖

មនុស្សឃាត ព្រោះមិនប្រយ័ត្ន មិនស្រប់ ឬ ធ្វេសប្រហែស ត្រូវផ្តន្ទាទោស មជ្ឈឹម ថ្នាក់ទីពីរ។


រក្សាសិទ្ធិ ©2004ដោយលេខាធិការដ្ឋានក្រុមការងាររាជរដ្ឋាភិបាល

មុនស្សឃាត ព្រោះមិនគោរពតាម បទបញ្ជា ត្រូវផ្តន្ទាទោស មជ្ឈិម ថ្នាក់ទីបី។

កាលបើ មនុស្សឃាត ដោយអចេតនា បណ្តាលមកពី ដាក់ថ្នាំពុល ដោយមិនប្រយ័ត្ន មិនប្រសប់ ដោយធ្វេសប្រហែស ឬ មិនគោរពតាម បទបញ្ជា មនុស្សឃាតនោះ ត្រូវផ្តន្ទាទោស ដូចគ្នាដោយវែកញែក តាមរបៀបខាងលើនេះដែរ។

ព្រះរាជ ប្រកាស លេខ ១៧៩ ចុះថ្ងៃ ១០-១១ ៣៦បានបន្ថែមថា៖

បទបញ្ញត្តិ ទាំងឡាយ ដែលមានគ្រាទុកក្នុងវគ្គទី៤ និងទី៥ នៃមាត្រា ៥៨៧ ក៏ត្រូវយកមក អនុវត្ត ក្នុងមាត្រានេះដែរ។

**មាត្រា ៥០៣** - កាលបើ មនុស្សឃាត បណ្តាលមកពី អំពើដែលប្រព្រឹត្តដោយចេតនា ត្រឹមតែចង់អោយឈឺរូបកាយ បុគ្គលណាម្នាក់ប៉ុណ្ណោះទេ មិនចង់អោយបុគ្គលនោះស្លាប់ទេ ប៉ុន្តែ អំពើនោះបណ្តាលអោយស្លាប់ បុគ្គលនោះ ទៅវិញ មនុស្សឃាតនេះ ត្រូវទុកជា បទមនុស្សឃាត គ្មានមរណចេតនាទេ ។ អ្នកមានពិរុទ្ធថ្នាក់នេះ ត្រូវមានទោស ឧក្រិដ្ឋ ថ្នាក់លេខមួយ។

**មាត្រា ៥០៤** - កាលបើ មនុស្សឃាត បណ្តាលមក ឬ អាចបណ្តាល មកពីចិត្ត ដែលស្ទុះ ឡើង ភ្លាមៗ ចង់អោយស្លាប់ មនុស្សឃាត នេះអោយឈ្មោះជាឃាតកម្ម ឬ បំណងឃាតកម្ម។

អ្នកមាន ពិរុទ្ធ ក្នុងបទនេះ ត្រូវមានទោស ថ្នាក់ទីមួយ។

**មាត្រា ៥០៥** - ចៅក្រម អាចសន្និដ្ឋានថា ឃាតករ មានមរណចេតនាបាន កាលណាបើ ឃាតករប្រហារ យ៉ាងពេញទំហឹង កាលណាបើមានមុខរបួសមុតសាំ លើខ្លួន អ្នកស្លាប់ កាលណាបើ ឃើញថាឃាតករ បានរើសរក កន្លែង ដំណំនៅលើខ្លួនអ្នកស្លាប់មែន។

**មាត្រា ៥០៦** - កាលណាបើ មនុស្សឃាត បណ្តាលមក ឬ បណ្តាលមកពី អំពើដោយចេតនា ឬពីបំណង ដោយចេតនា ហើយចេតនានោះ បានសំរេចដាច់ខាត ជាមុនផង មនុស្សឃាតនេះអោយ ឈ្មោះជា ហានកម្ម ឬ បំណងនៃហានកម្ម។

អ្នកមាន ពិរុទ្ធ ក្នុងបទនេះ ត្រូវមានទោស ឧក្រិដ្ឋថ្នាក់ទីបី។

**មាត្រា ៥០៧** - កាលណាបើ មនុស្សឃាត បណ្តាលមក ឬ អាចបណ្តាលមកពី វត្ថុ មានជាតិពុលដល់ស្លាប់ ដែលជនណាម្នាក់ដាក់ដោយចេតនា ចង់បំពុលមែន មនុស្សឃាតនេះ អោយឈ្មោះជា បទបំពុល ឬ បំណងក្នុងបទបំពុល។

អ្នកមាន ពិរុទ្ធ ក្នុងបទនេះ ត្រូវមានទោសឧក្រិដ្ឋ ថ្នាក់ទីបី។


រក្សាសិទ្ធិ ©2004ដោយលេខាធិការដ្ឋានក្រុមការងាររាជរដ្ឋាភិបាល

នាកាលវត្ថុ ដែលដាក់ដោយចេតនានោះ មិនមែនជាវត្ថុ មានជាតិពុលរហូតដល់ស្លាប់ទេ គឺមានជាតិពុល ត្រឹមតែបង្ខូចសុខភាពប៉ុណ្ណោះ ហើយក៏ស្រាប់តែបណ្តាលអោយស្លាប់ វិរុទ្ធជន ត្រូវមានទោស ឧក្រិដ្ឋ ថ្នាក់ទីបី។

**មាត្រា ៥០៨** - វត្ថុមាន ជាតិពុលនោះ ទោះមានប្រភេទដូចម្តេចក្តី ទោះមានវិធីដែលដាក់នោះដូចម្តេចក្តី ទោះរយៈពេលដែលត្រូវពុលស្លាប់នោះ មានកំណត់ប៉ុន្មានៗក្តី ក៏ត្រូវជាវត្ថុនោះ មានជាតិពុលដល់ស្លាប់ដែរ។

ប្រភព៖

បកប្រែ៖

វាយឡើងវិញ៖ដោយលេខាធិការដ្ឋានក្រុមការងាររាជរដ្ឋាភិបាល សំរាប់រៀបចំកាត់សេចក្តី មេដឹកនាំខ្មែរក្រហម


រក្សាសិទ្ធិ ©2004ដោយលេខាធិការដ្ឋានក្រុមការងាររាជរដ្ឋាភិបាល